ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ
លេខ៖ ៨៨៤
ចុះថ្ងៃទី១២-៩-២០១២

សាលដីកា
លេខ៖ ០៨ ក្រVI«វ»
ចុះថ្ងៃទី ០៩-៤-២០១៤

# តាងនាមប្រជារាស្ត្រខ្មែរ

# សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨-០២-១៩៩៣ បើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍ នៅថ្ងៃទី ២០-៣-២០១៤ ដោយមានសមាសភាពដូចតទៅ៖

**សមាសភាពក្រុមប្រឹក្សាជំនុំជំរះ**

លោក [redacted] ប្រធានក្រុមប្រឹក្សា
លោក [redacted] ចៅក្រមប្រឹក្សា
លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជី**

លោកស្រី [redacted]

-ដើម្បីជំនុំជំរះលើបណ្តឹងឧទ្ធរណ៍ នៃសំណុំរឿងព្រហ្មទណ្ឌលេខ៖ ៨៨៤ / ១២-៩-២០១២ រវាង៖

១-ជនជាប់ចោទឈ្មោះ [redacted] សារ៉ែន ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ មុខរបរ ធ្វើស្រែ កើតនៅភូមិគោកពេញ ឃុំជៀប ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង [redacted] ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ [redacted] «វ» ម្តាយឈ្មោះ [redacted] នៅរស់ ទោសពីមុនគ្មាន ឃុំខ្លួនថ្ងៃទី ២៨-៨-២០០៩ ។

២-ជនជាប់ចោទឈ្មោះ [redacted] ណាង ភេទប្រុស អាយុ២២ឆ្នាំ ជាតិខ្មែរ មុខរបរ ធ្វើស្រែ ទីលំនៅកំណើត និងបច្ចុប្បន្ន [redacted] ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ [redacted] «វ» ម្តាយឈ្មោះ [redacted] នៅរស់ ទោសពីមុនគ្មាន។

៣-ជនជាប់ចោទឈ្មោះ [redacted] រឹម ភេទប្រុស អាយុ១៩ឆ្នាំ ជាតិខ្មែរ មុខរបរ ធ្វើស្រែ ទីលំនៅកំណើត និងបច្ចុប្បន្ន [redacted] ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ [redacted] «វ» ម្តាយឈ្មោះ [redacted] «វ» នៅរស់ ទោសពីមុនគ្មាន ។

-លោក [redacted] ជួយ និងលោក [redacted] ម៉ាច ជាមេធាវីការពារសិទ្ធិ

៤-ជនជាប់ចោទឈ្មោះ [redacted]យ៉េត ភេទប្រុស អាយុ១៨ឆ្នាំ ជាតិខ្មែរ មុខរបរ ធ្វើស្រែ ទីលំនៅកំណើត និងបច្ចុប្បន្ន [redacted] ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ [redacted]«រ» ម្តាយឈ្មោះ [redacted]«រ» នៅលីវ ទោសពីមុនគ្មាន ។

ត្រូវចោទពីបទ៖ មនុស្សឃាតដោយចេតនាទៅលើឈ្មោះ [redacted] កាម និងជាប់ចោទពីបទបង្ករបួសដោយចេតនាលើឈ្មោះ [redacted]ទាំ ([redacted] ទាំ) ប្រព្រឹត្តនៅ ភូមិកោះខ្មុម ឃុំជៀប ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ២១ ខែមេសា ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និងមាត្រា ៤ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]ហ៊ីម ភេទប្រុស អាយុ៥៦ឆ្នាំ ជាតិខ្មែរឥស្លាម មុខរបរធ្វើស្រែ ទីលំនៅភូមិស្រែចាន ឃុំទួលខ្ពស់ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ជាឪពុករបស់ជនរងគ្រោះឈ្មោះ [redacted] ទាំ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៉ា ភេទប្រុស អាយុ៤០ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ ទីលំនៅភូមិស្រែចាន ឃុំទួលខ្ពស់ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ។

## ឯរឿងហេតុមានដូចតទៅ៖

កាលពីថ្ងៃទី ២១ ខែមេសា ឆ្នាំ២០០៩ វេលាម៉ោង ៤,៣០នាទីល្ងាច នៅចំណុចផ្លូវឆេះរទេះ ស្ថិតនៅភូមិកោះខ្មុម ឃុំជៀប ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង មានករណីបង្ករបួស ដែលបង្កឡើងដោយជនសង្ស័យបួននាក់គឺឈ្មោះ [redacted] សារ៉ាយ, [redacted] ណាង , [redacted] រីម និងឈ្មោះ [redacted] យ៉េត នាំគ្នាព្រួតវាយទៅលើជនរងគ្រោះឈ្មោះ [redacted]ទាំ ហៅ [redacted] ទាំ និងឈ្មោះ[redacted]កាម បណ្តាលឲ្យរងរបួសធ្ងន់ធ្ងរ ក្រោយមកក៏ស្លាប់បាត់បង់ជីវិតតែម្តង ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ៦៤(ក) ចុះថ្ងៃទី ៣១-៨-២០១០ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង ដែលបានសំរេចសេចក្តីដូចខាងក្រោម ៖

១-ផ្តន្ទាទោសលើជនជាប់ចោទ៖

ក-ឈ្មោះ [redacted]ហារ៉ន ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ(សាវតាជាតិក្នុងសំណុំរឿង) ដាក់ពន្ធនាគារកំណត់ចំនួន ១០ឆ្នាំ ០៦ខែ(ដប់ឆ្នាំប្រាំមួយខែ) គិតពីថ្ងៃទី ២៣ ខែមេសា ឆ្នាំ២០០៩ តទៅ ពីបទ៖ បង្ករបួសដោយចេតនាទៅលើជនរងគ្រោះឈ្មោះ [redacted] ទាំ និងពីបទមនុស្សឃាតដោយចេតនាទៅលើឈ្មោះ [redacted] កាម ប្រព្រឹត្តនៅភូមិកោះខ្មុម ឃុំជៀប ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ២១ ខែមេសា ឆ្នាំ២០០៩។ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និងមាត្រា ៤ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

ខ-ឈ្មោះ [redacted] ណាង ភេទប្រុស អាយុ២២ឆ្នាំ ជាតិខ្មែរ , ឈ្មោះ[redacted]យ៉េត ភេទប្រុស អាយុ១៩ឆ្នាំ ជាតិខ្មែរ , ឈ្មោះ[redacted]រីម ភេទប្រុស អាយុ១៨ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន ១០ឆ្នាំ ០៦ខែ(ដប់ឆ្នាំប្រាំមួយខែ) ក្នុងម្នាក់ៗ ដោយគិតពីថ្ងៃចាប់ខ្លួនបាន ពីបទ៖ បង្ករបួសដោយចេតនាទៅលើជន

រងគ្រោះឈ្មោះ [redacted] ទាំ និងពីបទ មនុស្សឃាដដោយចេតនាទៅលើឈ្មោះ [redacted] កាម ប្រព្រឹត្តនៅភូមិកោះខ្ចម ឃុំជៀប ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ២១ ខែមេសា ឆ្នាំ២០០៩ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៨១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និងមាត្រា ~~៤ នៃច្បាប់ស្តីពិ~~ ស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

២-បង្គាប់ឲ្យភ្នាក់ងារមានសមត្ថកិច្ចចាប់ខ្លួនជនជាប់ចោទឈ្មោះ [redacted] ណាង ,ឈ្មោះ [redacted] យ៉េត ឈ្មោះ [redacted] រីម មកដាក់ពន្ធនាគារខេត្តកំពង់ឆ្នាំង ដោយគិតចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

៣-បង្គាប់ឲ្យឈ្មោះ [redacted] សារ៉ន , [redacted] ណាង , [redacted] យ៉េត , [redacted] រីម រួមគ្នាសងសំណងរដ្ឋប្បវេណីទៅដើមបណ្តឹងឈ្មោះ [redacted] ទាំ សំរាប់ព្យាបាលរបួស និងជម្ងឺចិត្តចំនួន ១,០០០,០០០(មួយលាន)រៀល ទាមទារលើសពីនេះបដិសេធចោល គិតចាប់ពីថ្ងៃប្រកាសសាលក្រមចូលជាស្ថាពរតទៅ ។

៤-បង្គាប់ឲ្យឈ្មោះ [redacted] សារ៉ន, [redacted] ណាង , [redacted] យ៉េត, [redacted] រីម រួមគ្នាសងសំណងរដ្ឋប្បវេណីទៅដើមបណ្តឹងឈ្មោះ [redacted] ប៉ា សំរាប់ធ្វើបុណ្យសព និងជម្ងឺចិត្តចំនួន១៦,០០០,០០០រៀល(ដប់ប្រាំមួយលានរៀល) ទាមទារលើសពីនេះបដិសេធចោល គិតចាប់ពីថ្ងៃប្រកាសសាលក្រមចូលជាស្ថាពរតទៅ ។

៥-វត្ថុតាងរួមមានៈ ក្បាលខ្សែក្រវ៉ាត់ចំនួន ០២ និងឈើមួយកំណាត់ ត្រូវរឹបអូសបំផ្លាញចោលនៅពេលសាលក្រមចូលជាស្ថាពរ ។

៦-សាលក្រមនេះជំនុំជំរះជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សារ៉ន កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ណាង, [redacted] រីម, [redacted] យ៉េត និងចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះឈ្មោះ [redacted] ទាំ ទុកសិទ្ធិឲ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ដោយគិតចាប់ពីថ្ងៃទទួលបានលិខិតជូនដំណឹងនេះតទៅ ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ៧៣(ក) ចុះថ្ងៃទី ២៨-១១-២០១១ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង ដែលបានសំរេចសេចក្តីដូចខាងក្រោម ៖

១-ទទួលពាក្យបណ្តឹងទាស់ចុះថ្ងៃទី ២៨ ខែមេសា ឆ្នាំ២០១១ របស់ជនជាប់ចោទឈ្មោះ [redacted] រីម ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនិងគតិច្បាប់ ។

២-តម្កល់សាលក្រមលេខ ៦៨(ក) ចំណុច (ខ) ចុះថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០១០ ទុកជាបានការដដែល ។

៣-សាលក្រមនេះជំនុំជំរះជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ [redacted] រីម កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ណាង , [redacted] យ៉េត និងចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ ទុកសិទ្ធឲ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ៨៤ ក្រVI«រ» ចុះថ្ងៃទី ១៥-៧-២០១៣ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីដូចខាងក្រោម ៖

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ២១-១២-២០១២ របស់ឈ្មោះ [redacted] រីម ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខៈ ៧៣«ក» ចុះថ្ងៃទី ២៨-១១-២០១១ របស់សាលាដំបូងខេត្ត កំពង់ឆ្នាំង ទុកជាបានការ ។

៣-សាលដីកានេះប្រកាសជាសាធារណៈថ្ងៃទី ១៥-៧-២០១៣ កំបាំងមុខជនជាប់ចោទ និងដើម បណ្តឹងរដ្ឋប្បវេណី ។

បើកសិទ្ធិប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សាជំនុំជំរះសង្ខេបរបាយការណ៍រឿង

-ជនជាប់ចោទឈ្មោះ [redacted]ីម (ចូល)

-លោក [redacted]ជួយ និងលោក[redacted] ម៉ាច ជាមេធាវីការពារសិទ្ធិ (ចូល)

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហ៊ីម ឪពុករបស់ជនរងគ្រោះឈ្មោះ [redacted]ទាំ(មិនចូល)

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]ប៉ា (មិនចូល)

-ជនជាប់ចោទឈ្មោះ [redacted] រីម ថាៈ ខ្ញុំមានអាយុ ២៧ឆ្នាំ ។ ខ្ញុំមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ។ នៅថ្ងៃកើតហេតុខ្ញុំចាក់ធុងបាស់នៅវត្ត មិនបានដឹងរឿងគេវាយគ្នានៅកន្លែងផ្សេងទៀតនោះទេ ។ ឈ្មោះ [redacted] សារ៉ន , ឈ្មោះ [redacted] យ៉េត និងឈ្មោះ [redacted]ណាង ជាបក្សពួកគ្នា ។ ឈ្មោះ [redacted] សារ៉ន បានឆ្លើយនៅតុលាការថ្នាក់ក្រោមថាៈ មិនមែនឈ្មោះ រីម ជាខ្លួនទេ គឺឈ្មោះ រីម ផ្សេងទៀត ដែលហនតែម្តាយ ហើយមានរាងស្គមខ្ពស់ ។ ខ្លួនបានជួបឈ្មោះ [redacted]សារ៉ន និងផឹកស៊ីជាមួយគ្នានៅពេលព្រឹក ហើយម៉ោង ១២ថ្ងៃ ខ្ញុំទៅចាក់ធុងបាស់នៅវត្ត កើតហេតុវាយគ្នានៅពេលល្ងាច នៅកន្លែងផ្សេងទៀត ។ ខ្ញុំមិនបានរត់ទៅមើលកន្លែងកើតហេតុទេ ។ ខ្ញុំមានសាក្សីគឺ ចៅអធិការវត្ត និងឈ្មោះ[redacted]វីរៈ តែមិនបានឆ្លើយនៅតុលាការថ្នាក់ក្រោមទេ ។ ខ្ញុំមិនបានរត់ទៅមើលកន្លែងកើតហេតុទេ និងមិនបានរត់ទៅណាទេ ចន្លោះពីកើតហេតុដល់ពេលចាប់ខ្លួន ។ ខ្ញុំមិនបានឃើញប៉ូលីស និងប្រធានភូមិកោះហៅចូលតុលាការទេ ។ សូមតុលាការមេត្តាដោះលែងខ្ញុំឲ្យរួចផុតពីបទចោទ ។

-ក្រឡាបញ្ជីអានចម្លើយជនជាប់ចោទឈ្មោ[redacted] សារ៉ន នៅពេលសវនាការខេត្តកំពង់ឆ្នាំង ។

-ក្រឡាបញ្ជីរអានចម្លើយចៅអធិការវត្តឈ្មោះ[redacted]ហួត ។

តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋាន

យោងតាមការបដិសេធរបស់ជនជាប់ចោទ និងសាក្សីដែលបានអះអាងថា ឈ្មោះ រីម និងឈ្មោះ ណាង បានប្រព្រឹត្ត ហើយព្រះគ្រូចៅអធិការបានអះអាងថាឈ្មោះ រីម ទៅមិនដល់កន្លែងកើតហេតុ គឺការឆ្លើយដោះបន្ទុកនេះគឺពុំមានភស្តុតាងណាមកបញ្ជាក់ ដើម្បីឲ្យជនជាប់ចោទរួចផុតពីបទចោទឡើយ ហើយក៏ពុំមានភស្តុតាងណាថ្មីមកបញ្ជាក់ក្នុងអង្គសវនាការដែរ ។ មហាអយ្យការនៅតែសុំតម្កល់សាលដីកាទុកជាបានការដដែល ។

មេធាវីធ្វើសេចក្តីសន្និដ្ឋាន

-លោក [redacted] ម៉ាច ថាៈ កូនក្តីខ្ញុំនៅតែបដិសេធថា គាត់មិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ។ នៅថ្ងៃកើតហេតុគាត់ចាក់ធុងបាស់នៅក្នុងវត្ត ដែលមានលោកគ្រូចៅអធិការ និងឈ្មោះ [redacted] សុគន្ធា ដែលជាម្ចាស់ធុងបាស់បានបញ្ជាក់ថាៈ ឈ្មោះ រីម មិនបានទៅណាទេ ឈ្មោះ រីម ដែលត្រូវឈ្មោះ [redacted] សារ៉ន បញ្ជាក់នោះគឺមិនបានបញ្ជាក់ពីត្រកូលទេ និងគ្មានរបាយការណ៍ណាមួយដែលបញ្ជាក់ពីឈ្មោះ រីម ដែលមានតែម្តាយ ចំណែកកូនក្តីខ្ញុំមានទាំងឪពុក និងម្តាយ ។ ចម្លើយឈ្មោះ [redacted] សារ៉ន គឺឈ្មោះ រីម បិនដឹងឈ្មោះ រីម មួយណាទេ ។

-លោក [redacted] ជួយ ថាៈ ព្រះចៅអធិការវត្តគាត់ស្គាល់បាប និងបុណ្យណាស់ គឺគាត់មិនបានបំផ្លើសទេ ។ ចន្លោះកើតហេតុគេយកសពទៅបាត់ ទើបកូនក្តីខ្ញុំទៅមើល ។ ជនរងគ្រោះជាសាក្សីរស់ គាត់មិនបានចូលរួមសវនាការទេ គឺគ្មានការតទល់ឡើយ ហើយនៅតុលាការថ្នាក់ក្រោមគាត់សំអាងតែលើឈ្មោះ រីម ដែលឈ្មោះ [redacted] សារ៉ន ឆ្លើយដាក់បន្ទុកប៉ុណ្ណោះ ។ សុំចាត់របៀប និងធ្វើនីតិវិធីឡើងវិញ តែសុំលោកចៅក្រមពិនិត្យមើលលើសាក្សីដែលជាចៅអធិការវត្ត និងម្ចាស់ធុងបាស់ ។

តុលាការថយទៅពិភាក្សា

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ ។

-ក្រោយពីបានពិនិត្យឯកសារក្នុងសំណុំរឿងហើយ ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ។

-ក្រោយពីបានស្តាប់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋាន។

-ក្រោយពីបានស្តាប់សំណូមពររបស់ជនជាប់ចោទ ។

-ក្រោយពីបានពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

សាលាឧទ្ធរណ៍

យល់ឃើញថាៈ

១-បណ្តឹងទាស់ ចុះថ្ងៃទី ២១-៩-២០១៣ របស់ជនជាប់ចោទឈ្មោះ [redacted] រីម ប្តឹងទាស់នឹងសាលដីកាព្រហ្មទណ្ឌលេខៈ ៨៤ ក្រVI«វ» ចុះថ្ងៃទី ១៥-៧-២០១៣ របស់សាលាឧទ្ធរណ៍ ធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ យោងតាមមាត្រា ៤១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍ទទួលជំនុំជំរះបាន ។

២-ជនជាប់ចោទឈ្មោះ [redacted] រីម បានឆ្លើយនៅពេលសវនាការនេះថាៈ ខ្លួនមិនបានប្រព្រឹត្តដូចកាចោទប្រកាន់ទេ ខ្លួនមិនបានចូលរួមវាយជនរងគ្រោះទេ នៅថ្ងៃកើតហេតុនោះខ្លួនជាអ្នកចាក់ធុងបាស់ មុនពេលមកចាក់ធុងបាស់ ខ្លួនបានផឹកទឹកត្នោតជូរជាមួយឈ្មោះ [redacted] សារ៉ន តែពេលកើតហេតុវាយគ្នា ខ្លួនមិនបានចូលរួមទេ ។ ប៉ុន្តែតាមចម្លើយទណ្ឌិតឈ្មោះ [redacted] សារ៉ន បានបញ្ជាក់ថាៈ បក្សពួកខ្លួនរួមជាមួយឈ្មោះ [redacted] រីម ផងនោះ ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ប្រាកដមែន ។ ចំពោះការលើកឡើងរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ បានសុំឲ្យចាត់របៀប ដើម្បីរកឈ្មោះ រីម ពិតប្រាកដ ព្រោះ

ការអះអាងរបស់ឈ្មោះ [redacted] សារ៉ន មិនបានបញ្ជាក់ពីត្រកូលទេ ។ ចំណុចនេះ សាលាឧទ្ធរណ៍យល់ឃើញថា៖ ជនជាប់ចោទឈ្មោះ [redacted] រីម នេះ ពិតជាឈ្មោះ រីម ដែលឈ្មោះ [redacted] សារ៉ន បានឆ្លើយថា ជាបក្សពួករបស់ខ្លួនមែន ព្រោះជនជាប់ចោទឈ្មោះ [redacted] រីម នេះ ក៏បានទទួលស្គាល់ថា៖ មុនពេលចាក់ធុងបាស់ ខ្លួនពិតជាបានផឹកទឹកត្នោតជូរជាមួយឈ្មោះ [redacted] សារ៉ន ដែលស្របនឹងចំលើយរបស់ឈ្មោះ [redacted] សារ៉ន ។ ដូច្នេះ ការស្នើសុំឲ្យចាត់របៀបនេះ សាលាឧទ្ធរណ៍មិនពិចារណាឡើយ ។

៣-ជនជាប់ចោទឈ្មោះ [redacted] រីម ដែលជាដើមបណ្តឹងទាស់ នៅពេលនេះពុំមានភស្តុតាងណាថ្មីផ្សេងពីភស្តុតាងដែលមាននៅក្នុងសំណុំរឿងមកបញ្ជាក់ជូនសាលាឧទ្ធរណ៍ ដែលជាហេតុនាំឲ្យសាលាឧទ្ធរណ៍ពុំអាចកែប្រែសេចក្តីសម្រេចរបស់ខ្លួនបានឡើយ ។

៤-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការបានសន្និដ្ឋានថា៖ ពុំមានភស្តុតាងណាថ្មីមកបញ្ជាក់ក្នុងអង្គសវនាការឡើយ និងសុំតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ទុកជាបានការ ។

៥-សាលដីកាព្រហ្មទណ្ឌកំបាំងមុខលេខ៖ ៨៤ ក្រVI«វ» ចុះថ្ងៃទី ១៥-៧-២០១៣ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចមកនេះ មានលក្ខណៈត្រឹមត្រូវហើយ គប្បីតម្កល់ទុកជាបានការ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១/ទទួលបណ្តឹងទាស់ចុះថ្ងៃទី ២១-៩-២០១៣ របស់ជនជាប់ចោទឈ្មោះ [redacted] រីម ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោល ដោយផ្ទុយនឹងគតិច្បាប់ ។

២/តម្កល់សាលដីកាព្រហ្មទណ្ឌកំបាំងមុខលេខ៖ ៨៤ ក្រVI«វ» ចុះថ្ងៃទី ១៥-៧-២០១៣ របស់សាលាឧទ្ធរណ៍ ទុកជាបានការ ។

៣/បន្តការឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] រីម តាមនីតិវិធី ។

៤/សាលដីកានេះ ជំនុំជំរះជាសាធារណៈថ្ងៃទី ២០-៣-២០១៤ និងប្រកាសជាសាធារណៈថ្ងៃទី ០៩-៤-២០១៤ ចំពោះមុខជនជាប់ចោទឈ្មោះ ឡឹម រីម កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី ។

បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

**សេចក្តីនេះ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និងកងកំលាំងប្រដាប់អាវុធជួយសហការអនុវត្តសាលដីកានេះអោយបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។**

ក្រឡាបញ្ជី
ហត្ថលេខា៖ [redacted]

ចៅក្រមប្រឹក្សា
ហត្ថលេខា៖ [redacted] , [redacted]

ប្រធានក្រុមប្រឹក្សាជំនុំជំរះ
ហត្ថលេខា៖ [redacted]

បានឃើញ
ប្រធានសាលាឧទ្ធរណ៍
[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ,ថ្ងៃទី 19 ខែ មីនា ឆ្នាំ២០១៤
ក្រឡាបញ្ជី